NEWS RELEASE

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# ប្រមុខសិទ្ធិមនុស្ស អ.ស.ប សំដែងកង្វល់អំពីការបោះឆ្នោតនៅកម្ពុជា បន្ទាប់ពីមានការហាមប្រាមគណបក្សប្រឆាំង

ទីក្រុងហ្សឺណែវ (១៧ វិច្ឆិកា ២០១៧) – ប្រមុខសិទ្ធិមនុស្ស អ.ស.ប សំដែងកង្វល់ជាខ្លាំងនាថ្ងៃសុក្រនេះ អំពីការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងដែលអាចជឿទុកចិត្តបាននៅកម្ពុជា នៅឆ្នាំក្រោយនេះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់តុលាការកំពូល រំលាយគណបក្សប្រឆាំងដ៏ធំ ខណៈដែលមានការបង្ក្រាបលើសេរីភាពសារព័ត៌មាន និងសង្គមស៊ីវិលនៅទូទាំងប្រទេស។

តុលាការបានរំលាយគណបក្សសង្គ្រោះជាតិ (CNRP) ដែលជាគណបក្សប្រឆាំងដ៏សំខាន់ កាលពីថ្ងៃព្រហស្បតិ៍ បន្ទាប់ពីក្រសួងមហាផ្ទៃបានប្តឹងថា គណបក្សប្រឆាំងបានរៀបចំផែនការមួយ ដែលគេហៅថា បដិវត្តពណ៌ប្រឆាំងនឹងរដ្ឋាភិបាល។ សមាជិកសរុបចំនួន ១១៨ នាក់ នៃគណបក្សសង្គ្រោះជាតិ ត្រូវបានហាមឃាត់មិនឲ្យចូលរួមក្នុងសកម្មភាពនយោបាយរយៈពេលប្រាំឆ្នាំ។

ការរំលាយគណបក្សនេះ ធ្វើឡើងក្រោយការចាប់ខ្លួនប្រធានគណបក្សសង្គ្រោះជាតិ គឺលោក កឹម សុខា នៅថ្ងៃទី៣ ខែកញ្ញា ពីបទក្បត់ជាតិពាក់ព័ន្ធនឹងមតិយោបល់ដែលលោកបាននិយាយកាលពីឆ្នាំ២០១៣ អំពីយុទ្ធសាស្រ្តនយោបាយថ្នាក់មូលដ្ឋានរបស់លោក ដើម្បីប្រកួតប្រជែងជាមួយរដ្ឋាភិបាលបច្ចុប្បន្ន។

‟ ប្រជាធិបតេយ្យពហុបក្សដ៏មានប្រសិទ្ធភាពពិតប្រាកដមួយទាមទារឲ្យមានគណបក្សប្រឆាំងអាចប្រតិបត្តិការដោយសេរី ដោយគ្មានការបំភិតបំភ័យ និងការគំរាមកំហែង ហើយប្រជាធិបតេយ្យពហុបក្សនេះ ក៏ទាមទារសម្រាប់ការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងដែលអាចជឿទុកចិត្តបានផងដែរ″ នេះបើតាមប្រសាសន៍របស់ឧត្តមស្នងការ អ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្ស គឺលោក ហ្សេដ រ៉ាអាដ អាល់ហ៊ូសសេន។

‟ ការប្រើប្រាស់ច្បាប់ប្រឆាំងនឹងគណបក្សសង្គ្រោះជាតិ និងសមាជិករបស់គណបក្សនេះ គឺជាការបិទបាំងមួយ – វាគឺជាការគ្រប់គ្រងដោយច្បាប់ និងមិនមែនជាការគ្រប់គ្រងបែបនីតិរដ្ឋនោះទេ។ លោកបានមានប្រសាសន៍ថា ការចោទប្រកាន់ប្រឆាំងនឹងគណបក្សសង្គ្រោះជាតិ និងសមាជិករបស់គណបក្សនេះ មានភាពមិនច្បាស់លាស់ ហើយថាវាក៏មិនច្បាស់លាស់ផងដែរ ចំពោះបទប្បញ្ញត្តិច្បាប់ដែលគាំទ្របណ្តឹងសុំរំលាយគណបក្សនេះ″។ លោកមានប្រសាសន៍បន្ថែមទៀតថា ការរំលាយគណបក្សសង្គ្រោះជាតិ ត្រូវបានផ្អែកតែទៅលើការអះអាងចោទប្រកាន់ថាមានអំពើព្រហ្មទណ្ឌរបស់លោក កឹម សុខា ហើយដែលអំពើនេះ មិនត្រូវបានបញ្ជាក់បង្ហាញតាមរយៈភ័ស្តុតាងនៅក្នុងតុលាការនោះឡើយ។

លោក ហ្សេដ បានមានប្រសាសន៍ថា ការរំលាយគណបក្ស និងការហាមប្រាមចំពោះសមាជិកគណបក្សនេះ គឺជាបញ្ហាដែលគួរឲ្យព្រួយបារម្ភខ្លាំងមួយកម្រិតទៀត បន្ថែមលើវិធានការទាំងឡាយដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា។ នៅក្នុងប៉ុន្មានខែថ្មីៗនេះ រដ្ឋាភិបាលបានបិទ និងផ្អាកក្រុមសង្គមស៊ីវិល ព្រមទាំងក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយជាច្រើន ហើយរដ្ឋាភិបាលបាននិងកំពុងដាក់គោលដៅទៅលើអ្នកកាសែត និងសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលនានា។

បើតាមប្រសាសន៍របស់លោក ហ្សេដ "សមាសធាតុមួយដ៏សំខាន់នៃរបបប្រជាធិបតេយ្យទាំងអស់ គឺការធ្វើឲ្យសង្គមស៊ីវិលកាន់តែមានភាពរស់រវើក ដោយរួមបញ្ចូលទាំងអង្គការមិនមែនរដ្ឋាភិបាល និងសារព័ត៌មាន ដែលជូនកាលអាចរិះគន់រដ្ឋាភិបាលផងដែរ"។ " ការដាក់កំហិតលើសង្គមស៊ីវិលនិងការធ្វើឲ្យរួមតូចនូវលំហរបស់ពួកគេ គឺគ្រាន់តែជាការបង្អាក់គំនិតច្នៃប្រឌិត ការបង្កើតថ្មី និងភាពប៉ិនប្រសប់ ដែលចាំបាច់សម្រាប់កម្ពុជាក្នុងការបន្តការអភិវឌ្ឍ និងរក្សាសន្តិភាព។"

" ស្រដៀងគ្នានេះដែរ សារព័ត៌មានសេរី គឺមានសារៈសំខាន់ជាសារវ័ន្ត ដើម្បីធានាថា សាធារណជន ត្រូវបានគេផ្តល់ព័ត៌មានបានត្រឹមត្រូវអំពីបញ្ហានយោបាយ និងបញ្ហាដទៃផ្សេងទៀត ដើម្បីឲ្យមនុស្សទាំងឡាយអាចក្លាយជាតួអង្គដែលមានទំនួលខុសត្រូវ និងជាអ្នកចូលរួមចំណែកក្នុងភារកិច្ចទាំងនោះ" នេះបើតាមប្រសាសន៍របស់លោក។

" ប្រជាជនត្រូវការឲ្យមានលទ្ធភាពអាចជជែក និងពិភាក្សាដោយសេរី អំពីកិច្ចការនយោបាយរបស់ប្រទេសខ្លួន ហើយការសម្រេចចិត្តរំលាយគណបក្សសង្គ្រោះជាតិ បានដកហូតសិទ្ធិអ្នកតំណាងរបស់អ្នកបោះឆ្នោតជាងបីលាននាក់។"

**ចប់**

*សម្រាប់ព័ត៌មានបន្ថែម និងសំណើសុំព័ត៌មាន សូមទាក់ទងមក៖*

*នៅទីក្រុងហ្សឺណែវ៖ លោក ជេរេមី ឡូរិនស៍ (Jeremy Laurence ) តាមរយៈទូរស័ព្ទលេខ៖ +៤១ ២២ ៩១៧ ៩៣៨៣ ឬអ៊ីម៉ែល៖ jlaurence@ohchr.org) ឬ លោក រ៉ូប៊េត ខូលវីល (Rupert Colville) តាមរយៈទូរស័ព្ទលេខ៖ +៤១ ២២ ៩១៧ ៩៧៦៧ ឬអ៊ីម៉ែល៖* rcolville@ohchr.org)

*តើលោកអ្នកខ្វល់ខ្វាយអំពីពិភពលោកដែលយើងរស់នៅឬទេ? ដូច្នេះ* ***សូមក្រោកឈរឡើង ដើម្បីសិទ្ធិនរណាម្នាក់នៅថ្ងៃនេះ*** #Standup4humanrights *ហើយសូមចូលទៅកាន់ទំព័រវេបសាយ៖* http://www.standup4humanrights.org/en/

***ថេក និង ស៊ែរ - ទ្វីតធ័រ ៖ @UNHumanRights*** *និង* ***ហ្វេសប៊ុក៖ unitednationshumanrights***